THE SCHOOL DISTRICT OF PHILADELPHIA

**OFFICE OF THE SUPERINTENDENT**
440 North Broad Street
Philadelphia, PA 19130

**Dr. Tony B. Watlington Sr., Ed.D.**
Superintendent

ថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០២៣

ជូនចំពោះ ក្រុមគ្រួសាររបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖

ថ្ងៃនេះ អ្នកដឹកនាំសាលារាប់រយនាក់ គ្រូបង្រៀនរាប់ពាន់នាក់ និងបុគ្គលិកជំនួយរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ាទាំងអស់ចាប់ផ្តើមឆ្នាំសិក្សា ២០២៣-២០២៤។ ខ្ញុំរំភើបចិត្តយ៉ាងខ្លាំងក្នុងការស្វាគមន៍សិស្សត្រឡប់មកថ្នាក់រៀនវិញ។ ហើយខ្ញុំមានមោទនភាពយ៉ាងខ្លាំងចំពោះការងារដែលយើងបានធ្វើរួមគ្នាក្នុងរដូវក្តៅនេះដើម្បីជួយស្បានុសិស្ស និងក្រុមគ្រួសារឱ្យមានបទពិសោធន៍ដ៏ល្អនៅសាលា ក្នុងថ្នាក់រៀន និងពេលចូលរួមជាមួយក្រសួងអប់រំទាំងមូល។ នៅពេលយើងចាប់ផ្តើមនៅឆ្នាំនេះ លោកអ្នកអាចនឹងឃើញនូវអ្វីៗថ្មីៗ និងអ្វីៗដែលគួរឱ្យរំភើបចិត្តជាច្រើន ដែលយើងជឿថានឹងមានប្រយោជន៍សម្រាប់លោកអ្នក និងកូនរបស់លោកអ្នក៖

**<u>ចក្ខុវិស័យថ្មីសម្រាប់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា</u>**

និទាឃរដូវកន្លងទៅនេះ ខ្ញុំបានណែនាំបង្ហាញ *Accelerate Philly* – ផែនការយុទ្ធសាស្ត្រថ្មីរបស់ក្រសួងអប់រំ និងផែនទីបង្ហាញផ្លូវរបស់យើងសម្រាប់បម្រើសិស្ស បុគ្គលិក និងសហគមន៍ក្នុងរយៈពេលប្រាំឆ្នាំទៅមុខ។ ផែនការនេះបានឈានចូលដល់ដំណាក់កាលថ្មីសម្រាប់ក្រសួងអប់រំ ដោយបង្កើតបេសកកម្ម ចក្ខុវិស័យ និងទ្រឹស្តីនៃសកម្មភាពជាថ្មី ព្រមទាំងការបង្ហាញឱ្យឃើញនូវសកម្មភាពយុទ្ធសាស្ត្រចំនួន ៦២ ដែលយើងនឹងអនុវត្តក្នុងរយៈពេល ៥ ឆ្នាំខាងមុខ។ យើងកំពុងដំណើរការយ៉ាងឆាប់រហ័ស ហើយចាប់ផ្តើមសកម្មភាពទាំងនោះ ចំនួន ៣៧ នៅឆ្នាំសិក្សានេះ។ ខ្ញុំសូមអញ្ជើញលោកអ្នកឱ្យចូលមើល គេហទំព័រផែនការយុទ្ធសាស្រ (Strategic Plan website) ដើម្បីមើលផែនការទាំងអស់នេះ ប៉ុន្តែបន្ថែមលើយុទ្ធសាស្ត្រមួយចំនួនដែលបានអនុវត្តរួចហើយ (រួមទាំងគេហទំព័រថ្មី និងធនធានសម្រាប់ការបង្ហាត់បង្រៀនដែលបានពន្យល់ខាងក្រោមនេះ) អ្វីៗផ្សេងៗទៀតដែលលោកអ្នកអាចនឹងឃើញមាននៅក្នុងការអភិវឌ្ឍន៍នៅឆ្នាំនេះ រួមមាន:

- ការអភិវឌ្ឍន៍ ផែនការអគារសិក្សា (Facilities Master Plan) ដើម្បីបង្កើនសុវត្ថិភាព និងប្រសិទ្ធភាពនៃអគារសិក្សារបស់យើង។
- ធ្វើឱ្យប្រសើរឡើងនូវវិធានការសម្រាប់សុវត្ថិភាពផ្ទាល់ខ្លួននៅសាលា រួមទាំង បង្កើនសុវត្ថិភាពតាមផ្លូវ ម៉ាស៊ីនថតថ្មីៗសម្រាប់សុវត្ថិភាព និងបច្ចេកវិជ្ជារាវរកអាវុធដែលជ្រៀតជ្រែកក្នុងខ្លួនតែបន្តិចបន្តួច នៅសាលាមធ្យមសិក្សា (ថ្នាក់ទី ៥ ដល់ទី ៨)។
- បង្កើត ក្រុមប្រឹក្សាមាតាបិតា និងអាណាព្យាបាល ដែលចូលរួមជាទៀងទាត់ជាមួយខ្ញុំ និងថ្នាក់ដឹកនាំរបស់ខ្ញុំ។
- អនុវត្តការបង្រៀនបន្ថែមដែលមានឥទ្ធិពលខ្ពស់តាមដំណាក់កាល ដើម្បីជួយពន្លឿនជោគជ័យនៃការសិក្សា។
- ចាប់ផ្តើមដំណើរការប្រព័ន្ធទំនាក់ទំនងដែលមានច្រើនភាសា ដើម្បីបង្កើនទំនាក់ទំនងជាមួយក្រុមគ្រួសារ និង

សហគមន៍។

**<u>ធនធានសម្រាប់ការបង្ហាត់បង្រៀនសំខាន់ៗថ្មីៗ</u>**

ក្នុងអំឡុងនៃនិទាឃរដូវ និងរដូវក្តៅ យើងបានចែករំលែកថា ចាប់ពីឆ្នាំសិក្សានេះទៅ ក្រសួងអប់រំនឹងប្រើធនធានគណិតវិទ្យាកម្រិត ថ្នាក់មត្តេយ្យ ដល់ថ្នាក់ទី ១២ ដែលមានគុណភាពខ្ពស់ និងស្របតាមស្តង់ដារ ដែលត្រូវបានរៀបចំឡើងដើម្បីបំពេញកម្មវិធីសិក្សាគណិតវិទ្យារបស់យើង។ សូមអរគុណមួយផ្នែកធំចំពោះមតិកែលម្អដែលបានផ្តល់ដោយមាតាបិតារបស់ក្រសួងអប់រំជាច្រើននាក់ យើងបានជ្រើសរើស Imagine Learning LLC/Illustrative Mathematics ជាឈ្មួញដែលនឹងផ្តល់ធនធានថ្មីៗ។ គ្រូបង្រៀន នាយកសាលា និងឪពុកម្តាយរាប់រយនាក់ត្រូវបានហ្វឹកហ្វឺន និងណែនាំអំពីធនធានថ្មីៗទាំងនេះ ហើយខ្ញុំទន្ទឹងរង់ចាំមើលអ្វីៗទាំងនេះក្នុងការអនុវត្តនៅឆ្នាំនេះ។ ស្វែងយល់បន្ថែមដោយចូលទៅកាន់ គេហទំព័រកម្មវិធីសិក្សា (curriculum website) របស់យើង។

**<u>ការកែសម្រួលគេហទំព័រឡើងវិញ</u>**

គេហទំព័ររបស់ក្រសួងអប់រំ និងគេហទំព័រជំនួយការសិក្សា និងសិស្សទាំងអស់ត្រូវបានកែសម្រួលឡើងវិញ ដើម្បីឱ្យកាន់តែច្បាស់ និងងាយស្រួលប្រើជាងមុន។ ការរចនាទំព័រត្រូវបានសម្រួលទៅជាគំរូដែលស្របគ្នា ខ្លឹមសារទំព័រត្រូវបានសរសេរឡើងវិញដើម្បីលើកកម្ពស់ការយល់ដឹង ហើយមជ្ឈមណ្ឌលព័ត៌មានសម្រាប់សិស្ស និងក្រុមគ្រួសារ ត្រូវបានបន្ថែម – ទាំងអស់នេះគឺជាគោលបំណងដើម្បីជួយលោកអ្នកស្វែងរកព័ត៌មានដែលលោកអ្នកត្រូវការបានកាន់តែលឿន។ ធ្វើយ៉ាងណាសូមចូលមើលគេហទំព័រ www.philasd.org ។

ជាការពិតណាស់ វិធីល្អបំផុតដើម្បីចាប់ផ្តើមឆ្នាំសិក្សាថ្មីគឺត្រូវបង្ហាញខ្លួននៅថ្ងៃដំបូង! ការចូលរៀនប្រចាំថ្ងៃមានសារៈសំខាន់សម្រាប់ភាពជោគជ័យក្នុងការសិក្សារបស់សិស្ស និងសមត្ថភាពយល់ដឹង និងគ្រប់គ្រងអារម្មណ៍ និងទំនាក់ទំនងក្នុងសង្គម។ កាលពីឆ្នាំសិក្សាមុន ការចូលរួមរបស់គ្រូ និងសិស្សបានកើនឡើង ហើយចំនួនសិស្សបោះបង់ការសិក្សាក៏ថយចុះ។ សូមរក្សាសន្ទុះវិជ្ជមាននោះក្នុងឆ្នាំសិក្សា ២០២៣-២០២៤!

ជាការពិតណាស់ ថ្ងៃនេះជាការចាប់ផ្តើមនៃអនាគតដ៏រំភើបសម្រាប់សហគមន៍របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា – ជាកន្លែងមួយដែលក្មេងនៃទីក្រុងហ្វីឡាដែលហ្វ្យានឹងត្រូវត្រៀមខ្លួនយ៉ាងគ្រប់គ្រាន់ដើម្បីស្រមៃ និងសម្រេចបាននូវអនាគតដែលពួកគេចង់បាន។ នេះជាចក្ខុវិស័យដ៏ធំធេង ប៉ុន្តែអាចសម្រេចបានប្រសិនបើយើងធ្វើបន្តរួមគ្នា!

ក្នុងភាពជាដៃគូ

*Tony*

Tony B. Watlington Sr., Ed.D.
អគ្គនាយកក្រសួងអប់រំ
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា